

ការពិត

# ការយល់ដឹងអំពី ប្រព័ន្ធសុខាភិបាល អូស្ត្រាលី

Khmer | ខ្មែរ

## ការស្វែងរកវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV (វីរុសបង្កឱ្យកើតជំងឺអេដស៍)

អ្នកត្រូវការវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ម្នាក់ដើម្បីជួយអ្នកគ្រប់គ្រង និងព្យាបាលមេរោគ HIV របស់អ្នក។ មានតែវេជ្ជបណ្ឌិតដែលបានទទួលការបណ្តុះបណ្តាលពិសេសប៉ុណ្ណោះ ដែលអាចធ្វើកិច្ចការនេះបាន។ ប្រសិនបើវេជ្ជបណ្ឌិតដែលបានធ្វើតេស្ត និងធ្វើរោគវិនិច្ឆ័យអ្នក មិនមែនជាវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ទេនោះ អ្នកនឹងត្រូវបញ្ជូនទៅវេជ្ជបណ្ឌិតដែលមានការបណ្តុះបណ្តាលផ្នែកព្យាបាលមេរោគ HIV។ អ្នកនៅតែអាចទៅជួបវេជ្ជបណ្ឌិតរបស់អ្នកសម្រាប់បញ្ហាសុខភាពផ្សេងទៀត ប្រសិនបើអ្នកចង់។ វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ត្រូវបានបណ្តុះបណ្តាលក្នុងការគ្រប់គ្រង និងព្យាបាលមេរោគ HIV ហើយជាវេជ្ជបណ្ឌិតតែមួយគត់ដែលអាចចេញវេជ្ជបញ្ជាការព្យាបាលមេរោគ HIV។ **អ្នក** មានសិទ្ធិជ្រើសរើសវេជ្ជបណ្ឌិតឯកទេសព្យាបាលមេរោគ HIV របស់អ្នក។

វេជ្ជបណ្ឌិតឯកទេសព្យាបាលមេរោគ HIV អាចជា៖

- អ្នកឯកទេសជំងឺឆ្លងនៅមន្ទីរពេទ្យ
- វេជ្ជបណ្ឌិតនៅគ្លីនិកសុខភាពផ្លូវភេទ
- វេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (GPs) ដែលបានទទួលការបណ្តុះបណ្តាលក្នុងការព្យាបាល និងការគ្រប់គ្រងមេរោគ HIV ជាទូទៅគេហៅពួកគាត់ថាវេជ្ជបណ្ឌិតចេញវេជ្ជបញ្ជា S100

## តួនាទីរបស់វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នក

វេជ្ជបណ្ឌិតរបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីគ្រប់គ្រង និងព្យាបាលមេរោគ HIV របស់អ្នក និងរក្សាអ្នកឱ្យមានសុខភាពល្អ។

### *ការទៅជួបវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV ជាលើកដំបូងរបស់អ្នក*

នៅក្នុងការទៅជួបលើកដំបូងរបស់អ្នក វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នកនឹង៖

- ធ្វើតេស្តប្រព័ន្ធភាពស៊ាំរបស់អ្នក (ការរាប់ចំនួនកោសិកា CD4)
- ពិនិត្យសុខភាពទូទៅរបស់អ្នក
- ធ្វើតេស្តឈាមលើចំនួនវីរុស
- ពិនិត្យមើលភាពធន់នឹងការព្យាបាល។

ពួកគេក៏នឹងនិយាយជាមួយអ្នកអំពីសុខភាពទូទៅរបស់អ្នក ស្ថានភាពសុខភាពផ្សេងទៀត និងការគាំទ្រណាមួយដែលអាចជួយអ្នក ក្នុងការធ្វើរោគវិនិច្ឆ័យថ្មីរបស់អ្នកផងដែរ។

### *ការចេញវេជ្ជបញ្ជាឱសថរបស់អ្នក*

នេះត្រូវបានណែនាំឱ្យអ្នកចាប់ផ្តើមការព្យាបាល ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានទទួលការធ្វើរោគវិនិច្ឆ័យមេរោគ HIV រួច។ នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់មនុស្សដែលមានចំនួនកោសិកា CD4 ទាប អ្នកដែលមានស្ថានភាពសុខភាពផ្សេងៗទៀតទាក់ទងនឹងមេរោគ HIV និងអ្នកដែលមានផ្ទៃពោះ។ វេជ្ជបណ្ឌិតរបស់អ្នកនឹងពិភាក្សាអំពីការព្យាបាលជាមួយអ្នកដើម្បីរកមើលថាតើឱសថមួយណា ត្រឹមត្រូវសម្រាប់អ្នក។

### *តាមដានសុខភាពរបស់អ្នក*

វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV របស់អ្នក នឹងពិនិត្យសុខភាពរបស់អ្នកដោយការធ្វើតេស្តឈាមទៀងទាត់។ សូមសួរវេជ្ជបណ្ឌិតរបស់អ្នក ថាតើអ្នកត្រូវការជួបពួកគេញឹកញាប់ប៉ុណ្ណាដែរ។ ដំបូងអ្នកប្រហែលជាទៅជួបពួកគាត់ញឹកញាប់ ប៉ុន្តែនេះនឹងត្រូវកាត់បន្ថយទៅតាមពេលវេលា (រៀងរាល់3-ខែ 6ខែ ឬប្រចាំឆ្នាំ)។ សម្រាប់ព័ត៌មានបន្ថែម សូមមើល *ប័ណ្ណការពិតស្តីពីការតាមដានសុខភាពរបស់អ្នក*។

## ការជ្រើសរើសវេជ្ជបណ្ឌិតដែលត្រឹមត្រូវសម្រាប់អ្នក

វាមានសារៈសំខាន់ណាស់ក្នុងការស្វែងរកវេជ្ជបណ្ឌិតម្នាក់ដែលអ្នកអាចនិយាយជាមួយ និងជឿទុកចិត្តបាន និងធ្វើការរួមគ្នាជាមួយក្រុមថែទាំសុខភាពមេរោគ HIV របស់អ្នក។ ក្រុមថែទាំសុខភាពមេរោគ HIV របស់អ្នក អាចរួមមានវេជ្ជបណ្ឌិតព្យាបាលមេរោគ HIV, គិលានុបដ្ឋាក HIV, peer navigator (អ្នកលើកទឹកចិត្តអ្នកដទៃដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា) អ្នកចិត្តសាស្ត្រ បុគ្គលិកសង្គមកិច្ច ឬអ្នកប្រឹក្សាយោបល់ និងបុគ្គលិកសុខាភិបាលផ្សេងទៀត។

ប្រសិនបើអ្នកកំពុងជួបវេជ្ជបណ្ឌិតម្នាក់ដែលអ្នកមិនមានអារម្មណ៍ត្រឹមត្រូវ អ្នកអាចផ្លាស់ប្តូរវេជ្ជបណ្ឌិតបាន។ អ្នកក៏អាចផ្លាស់ប្តូររវាងមន្ទីរពេទ្យ គ្លីនិកសុខភាពផ្លូវភេទ និងគ្លីនិក GP ឬស្នើសុំផ្លាស់ប្តូរវេជ្ជបណ្ឌិតនៅក្នុងគ្លីនិកទាំងនេះបាន។ វាជាជម្រើសរបស់អ្នកទេ។

អ្នកខ្លះមានវេជ្ជបណ្ឌិតពីរនាក់ វេជ្ជបណ្ឌិតព្យាបាលមេរោគ HIV និង GP សម្រាប់សុខភាពទូទៅ។ អ្នកផ្សេងទៀតមាន GP ចេញវេជ្ជបញ្ជា S100 ដែលពួកគេទៅជួបសម្រាប់ពិនិត្យមេរោគ HIV ក៏ដូចជាសុខភាពទូទៅរបស់ពួកគេផងដែរ។

ប្រសិនបើអ្នករស់នៅក្រៅទីក្រុងមែលប៊ន អ្នកប្រហែលជាមានជម្រើសតិចជាងអំពីការថែទាំមេរោគ HIV នៅក្នុងតំបន់របស់អ្នក។ អ្នកក៏អាចព្រួយបារម្ភអំពីរឿងសម្ងាត់ផ្ទាល់ខ្លួនផងដែរ។ Living Positive Victoria Peer Navigator (រស់នៅប្រកបដោយវីរុសមានក្នុងរដ្ឋវិចថូរៀ អ្នកលើកទឹកចិត្តអ្នកដទៃដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា) អាចជួយអ្នកស្វែងរកវេជ្ជបណ្ឌិតដែលសមស្របសម្រាប់អ្នក។

### *អ្វីដែលត្រូវប្រាប់ក្រុមថែទាំសុខភាពរបស់អ្នក*

- អារម្មណ៍ដែលអ្នកកំពុងមាន
- ឱសថផ្សេងទៀតដែលអ្នកកំពុងប្រើ (រួមទាំងឱសថដែលមិនមានវេជ្ជបញ្ជា និងថ្នាំបំប៉ននានា)
- អ្វីដែលអ្នកបរិភោគ និងផឹក កាហ្វេអ៊ីន និងគ្រឿងស្រវឹង ការប្រើប្រាស់គ្រឿងញៀន និងថ្នាំជក់
- ការផ្លាស់ប្តូរ ឬកង្វល់ណាមួយ ផលប៉ះពាល់ លំនាំនៃការគេង អារម្មណ៍

## *អ្វីដែលត្រូវសួរក្រុមថែទាំសុខភាពរបស់អ្នក*

- តើខ្ញុំគួរចាប់ផ្តើមការព្យាបាលមេរោគ HIV ឬទេ (ប្រសិនបើអ្នកមិនទាន់បានចាប់ផ្តើម)?
- តើខ្ញុំគួររកមើលផលប៉ះពាល់អ្វីខ្លះ?
- តើអ្វីជាចំនួនវីរុសរបស់ខ្ញុំ (បរិមាណវីរុសក្នុងឈាមរបស់ខ្ញុំ)?
- តើការរាប់ចំនួនកោសិកា CD4 របស់ខ្ញុំជាអ្វី (មុខងារប្រព័ន្ធភាពស៊ាំ)?
- តើការព្យាបាលរបស់ខ្ញុំដំណើរការទេ? តើខ្ញុំត្រូវការផ្លាស់ប្តូរអ្វីទេ?
- តើមានអ្វីដែលខ្ញុំកំពុងលេប ឬប្រើ អាចមានប្រតិកម្មជាមួយនឹងការព្យាបាលរបស់ខ្ញុំទេ?
- តើខ្ញុំអាចកែលម្អសុខភាព និងសុខុមាលភាពរបស់ខ្ញុំដោយរបៀបណា?

## *ជំនួយលើការធ្វើដំណើរ*

Victorian Patient Transport Assistance Scheme (VPTAS) ជួយក្នុងការធ្វើដំណើរ និងថ្លៃស្នាក់នៅ។ គ្រោងការណ៍នេះគឺសម្រាប់អ្នកដែលរស់នៅក្នុងជនបទរដ្ឋវិចថូរៀ ដែលត្រូវការធ្វើដំណើរលើសពី 100 គីឡូម៉ែត្រតែទៅ ឬមក ឬជាមធ្យម 500 គីឡូម៉ែត្រក្នុងមួយសប្តាហ៍ ដើម្បីទទួលសេវាកម្មឯកទេសវេជ្ជសាស្ត្រ ឬការព្យាបាលធ្មេញឯកទេសដែលទទួលបានការអនុញ្ញាត។

ក្រុមគាំទ្រខភាពសហគមន៍សុ Thorne Harbour មានអ្នកស្ម័គ្រចិត្តផ្តល់ការដឹកជញ្ជូនសម្រាប់អ្នកទាំងឡាយណាដែលមិនអាចអញ្ជើញ ទៅជួបតាមការណាត់របស់ពេទ្យ។

សម្រាប់ព័ត៌មានបន្ថែម សូមមើលកូដ QR នៅចុងបញ្ចប់។

## សម្រាប់ព័ត៌មានបន្ថែម